Received by NSD/FARA Registration Unit 08/17/2025 1:41:30 PM

**KINGDOM OF CAMBODIA**

**NATION RELIGION KING**

**MINISTRY OF CULTURE AND FINE ARTS**

№.........✓.................

Phnom Penh,...22....August.......,2024.

**PRESS RELEASE**

**A Celebration of Returned Khmer Artifacts to the Kingdom of Cambodia**

The Ministry of Culture and Fine Arts is honored to inform the public that on 22 August 2024, a "Celebration of Returned Khmer Artifacts to the Kingdom of Cambodia" was held under the high presidency of **Samdech Moha Borvor Thipadei HUN MANET, Prime Minister of the Kingdom of Cambodia,** at the Peace Palace, Phnom Penh, to welcome the return of cultural treasures, which are the legacy of our ancestors, after being away from their homeland for many years due to war, theft, and illegal trade abroad.

The return of these Khmer ancestors' souls is the result of the great efforts of the Royal Government of Cambodia, in cooperation with all relevant partners, including public institutions, private sectors, national and international experts, as well as various countries, especially the Government of the United States, through the U.S. Attorney's Office for the Southern District of New York (SDNY), Homeland Security Investigations (HSI), Manhattan District Attorney's Office. The Ministry is especially grateful to the efforts of its legal advisors, Bradley J. Gordon and Steve Andrew Heimberg, for their many years of commitment working with the Cambodian team to reclaim Cambodia's lost cultural treasures.

Recently, a total of 70 Khmer cultural objects have been returned through a range of different processes, including voluntary returns, negotiations, seizures, and legal proceedings, from different collections such as from the Lindemann family, Jim Clark, the Metropolitan Museum of Art in New York, and other private collectors in the United States. Amongst the returned Khmer cultural treasures, there are some important Hindu and Buddhist masterpieces from pre-Angkor and Angkor periods, especially priceless stone statues such as a mythical warrior from the Hindu epic *Mahabharata*, statues of Shiva and Uma, and the statue of Ardhanarishvara from the ancient capital of Koh Ker, as well as the bronze head of Lokeshvara, which has been reunited with its body at the National Museum of Phnom Penh after being separated for decades due to war and illicit trafficking.

The peace brought by the Win-Win Policy of **Samdech Akka Moha Sena Padei Techo Hun Sen** has provided an opportunity for Cambodia to bring back the souls of ancestors and precious treasures to their homeland. The Royal Government of Cambodia of the Seventh Legislature of the National Assembly, under the wise leadership of **Samdech Maha Borvor Thipadei Hun Manet, Prime Minister of the Kingdom of Cambodia**, has continued this historic policy with strong commitment to protect and prevent the trafficking and illegal trade

Address : 227, Preah Norodom Blvd., Khan Chamkar Mon,
Phnom Penh, Kingdom of Cambodia.

Tel : (855) 23 217 647
Fax : (855) 23 218 146

Received by NSD/FARA Registration Unit 08/17/2025 1:41:30 PM

Received by NSD/FARA Registration Unit 08/17/2025 1:41:31 PM

of cultural properties, as well as to search for and reclaim national heritage to build an enduring legacy for Cambodia's cultural and national identity for future generations.

The Cambodian people are proud and filled with joy for the return of these national treasures representing our ancestral souls and identity, under the umbrella of peace and development.

May the souls of the Khmer ancestors who returned to their homeland help bring the Kingdom of Cambodia peace, prosperity, and harmony forever.

Received by NSD/FARA Registration Unit 08/17/2025 1:41:31 PM

Received by NSD/FARA Registration Unit 08/17/2025 1:41:32 PM

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការរៀបចំពិធីទទួលវត្ថុបុរាណខ្មែរ ដែលបានប្រគល់ជូនព្រះរាជាណាចក្រកម្ពុជាវិញ

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានកិត្តិយសសូមជម្រាបជូនសាធារណជនជ្រាបថា នាព្រឹកថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤ ក្រសួងបានរៀបចំ "**ពិធីទទួលវត្ថុបុរាណខ្មែរ ដែលបានប្រគល់ជូនព្រះរាជាណាចក្រកម្ពុជាវិញ**"ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រ**កម្ពុជា** នៅវិមានសន្តិភាព រាជធានីភ្នំពេញ ដើម្បីទទួលស្វាគមន៍ការវិលត្រឡប់មកវិញនៃសម្បត្តិវប្បធម៌ជាតិដែលជាកេរដំណែលដូនតា បន្ទាប់ពីបានរសាត់ចាកឆ្ងាយពីមាតុភូមិកំណើតអស់រយៈពេលជាច្រើនឆ្នាំ ដែលបង្កឡើងដោយសង្គ្រាម អំពើចោរកម្ម និងការជួញដូរខុសច្បាប់ទៅក្រៅប្រទេស។

ការយាងត្រឡប់មកវិញនៃព្រលឹងដូនតាខ្មែរនាពេលនេះ គឺជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងជាប់មិនដាច់របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធ ទាំងស្ថាប័នរដ្ឋ ផ្នែកឯកជន អ្នកជំនាញជាតិនិងអន្តរជាតិ ព្រមទាំងជាមួយប្រទេសនានា ជាពិសេស រដ្ឋាភិបាលសហរដ្ឋអាមេរិក តាមរយៈរដ្ឋអាជ្ញាសង្កាត់ភាគខាងត្បូងក្រុងញូវយ៉ក, ការិយាល័យស៊ើបអង្កេតសន្តិសុខមាតុភូមិ និងការិយាល័យរដ្ឋអាជ្ញាសង្កាត់ម៉ាន់ហាថាន។ ក្រសួងសូមសម្តែងនូវការកោតសរសើរជាពិសេសដល់លោក Bradley J. Gordon និងលោក Steve Andrew Heimberg ជាទីប្រឹក្សាផ្នែកច្បាប់ ចំពោះការខិតខំប្រឹងប្រែងអស់រយៈពេលជាច្រើនឆ្នាំជាមួយក្រុមការងារកម្ពុជា ដើម្បីទាមទារយកមរតកវប្បធម៌ដែលបានបាត់បង់ត្រឡប់មកវិញ។

សម្បត្តិវប្បធម៌ខ្មែរសរុបចំនួន៧០រូបដែលទទួលនាពេលនេះ តាមរយៈការប្រគល់ដោយស្ម័គ្រចិត្ត ការចរចា ការរឹបអូស ការទាមទារ និងតាមផ្លូវតុលាការ បានត្រូវប្រគល់មកវិញពី៖ គ្រួសារ Lindemann, លោក James Clark និងសារមន្ទីរ Metropolitan Museum of Art នៅទីក្រុងញូវយ៉ក, ព្រមទាំងពីម្ចាស់សមុច្ច័យឯកជននានានៅសហរដ្ឋអាមេរិក។ ក្នុងចំណោមវត្ថុពិចិត្រទាំងនេះមានរូបបដិមាសំខាន់ៗមួយចំនួនផ្នែកព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ក្នុងសម័យមុនអង្គរ និងសម័យអង្គរ ជាពិសេសបដិមាថ្មធំៗដ៏ប្រណីតដូចជា បដិមាទេពនៃទេវកថាមហាភារតៈ, បដិមាព្រះឥសូរ នាងឧមា និងបដិមាព្រះអឌ្ឍនារីស្វរៈ មកពីអតីតរាជធានីកោះកេរ ព្រមទាំងព្រះសិរនៃព្រះលោកេស្វរ ដែលត្រូវបានផ្គុំភ្ជាប់ឡើងវិញជាមួយនឹងដងខ្លួនរបស់ព្រះអង្គស្ថិតនៅសារមន្ទីរជាតិភ្នំពេញ ក្រោយពីបានព្រាត់ចាកឆ្ងាយពីគ្នាអស់រយៈពេលរាប់សិបឆ្នាំ ដោយសារសង្គ្រាម និងការជួញដូរខុសច្បាប់។

សន្តិភាពដែលកើតចេញពីនយោបាយឈ្នះ-ឈ្នះរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានផ្តល់ឱកាសឱ្យកម្ពុជាអាចនាំយកនូវព្រលឹងដូនតា និងរតនសម្បត្តិដ៏មានតម្លៃនានាដែលបានបាត់បង់កន្លងមកត្រឡប់មកមាតុភូមិកំណើតវិញជាបន្តបន្ទាប់ ដែលជាការជួបជុំគ្នាឡើងវិញនៃមហាគ្រួសារខ្មែរ និងជាមង្គលសម្រាប់ប្រជាជាតិ និងប្រជាជនកម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧នៃរដ្ឋសភា ក្រោមការ



Received by NSD/FARA Registration Unit 08/17/2025 1:41:32 PM

ដឹកនាំប្រកបដោយគតិបណ្ឌិតនិងភាពឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានបន្តនូវគោលនយោបាយជាប្រវត្តិសាស្ត្រនេះ ប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ក្នុងការការពារ ទប់ស្កាត់ ការចរាចរ និងការជួញដូរខុសច្បាប់នៃសម្បត្តិវប្បធម៌ ក៏ដូចជាការស្វែងរក និងទាមទារយកមកវិញនូវមរតកវប្បធម៌ជាតិ ដើម្បីទុកជាកេរដំណែលវប្បធម៌និងអត្តសញ្ញាណជាតិសម្រាប់កូនខ្មែរជំនាន់ក្រោយ។

ប្រជាជនកម្ពុជាទាំងមូលពិតជាមានមោទនភាព និងសេចក្តីរំភើបរីករាយឥតឧបមា ជាមួយនឹងការអបអរសាទរអស់ពីដួងចិត្ត ចំពោះការវិលត្រឡប់មកវិញនូវរតនសម្បត្តិវប្បធម៌ដែលជាព្រលឹងដូនតារបស់ខ្លួន និងជាអត្តសញ្ញាណជាតិ ក្រោមម្លប់នៃសុខសន្តិភាព និងការអភិវឌ្ឍលើគ្រប់វិស័យ។

សូមព្រលឹងបារមីនៃបុព្វបុរសខ្មែរ ដែលបានយាងត្រឡប់មកមាតុភូមិកំណើតវិញនេះ តាមជួយបីបាច់ថែរក្សាព្រះរាជាណាចក្រកម្ពុជាឱ្យជួបតែនឹងសុខសន្តិភាព វិបុលភាព និងសុខដុមរមនាជានិច្ចនិរន្តរ៍។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤

"អរគុណសន្តិភាព"